

នាវសៀលថ្ងៃមួយ យ៉េកកំពុងដឹកខេទីនិងលោកគ្រូសុខនៅលើរ៉ឺម៉កកង់បីរបស់គាត់ ដើម្បីជិះដើរលេង។ ស្រាប់តែពួកគាត់បានប្រទះឃើញរតនានិងមករាកំពុងលេងនៅតាមផ្លូវ។ ខេទីក៏ស្រែកសួរ « តើអ្នកទាំងពីរចង់ឡើងមកជិះរ៉ឺម៉កកង់បី ដើរលេងជាមួយពួកយើងដែរឬទេ?» ឮដូចនេះ កុមារទាំងពីរនាក់សប្បាយត្រេកអរយ៉ាងខ្លាំង ហើយក៏ហក់ឡើងរ៉ឺម៉កកង់បី ជាមួយពួកគេតែម្តង។




ខណៈពេលដែលពួកគាត់ទាំងអស់គ្នា កំពុងជិះរ៉ឺម៉កកង់បីដើរលេង ស្រាប់តែរតនាប្រាប់យ៉េកនិងខេទី « ខ្ញុំពូកែគណិតណាស់។ ថ្ងៃនេះ ថ្នាក់របស់ខ្ញុំប្រឡងហើយ ខ្ញុំបានលេខមួយទៀតហ៎! »




មករាក៏និយាយ « ឯខ្ញុំវិញពូកែភាសាខ្មែរ ខាងប្រកបពាក្យខ្លាំងណាស់។ ថ្ងៃនេះ ថ្នាក់របស់ខ្ញុំក៏ប្រឡងដែរ ហើយខ្ញុំប្រកបត្រូវគ្រប់ពាក្យ។ ចុះយ៉េកវិញពូកែខាងអ្វីដែរ? »



យ៉េកឆ្លើយ « ខ្ញុំខ្ពស់ ហើយខ្ញុំអាចឈោងដៃដល់កន្លែងខ្ពស់ៗជាច្រើន »



លោកគ្រូសុខក៏ឆ្លើយដែរ « លោកគ្រូវិញមានកម្លាំងខ្លាំង។ លោកគ្រូអាចលើករបស់ធ្ងន់ៗ បានជាច្រើន »



ចំណែកឯ ខេទីវិញនៅស្ងៀម។
« ចុះខេទីវិញ? តើអ្នកពូកែខាងអ្វីដែរ? »
ខេទីគិតមួយសន្ទុះ រួចក៏សម្រេចចិត្តឆ្លើយទាំងទឹកមុខស្រពាប់ស្រពោន
« ខ្ញុំគិតថា ខ្ញុំដូចជាអត់មានពូកែខាងអ្វីសោះហើយ »



និយាយដល់ត្រឹមនេះ ពួកគាត់ក៏ជិះមកដល់កន្លែង ដែលលោកគ្រូសុខចូលចិត្តមកអង្គុយលំហែកាយលេង។ លោកគ្រូសុខក៏បាននិយាយ « ឱ្យតែលោកគ្រូមានពេលទំនេរ លោកគ្រូចូលចិត្តមកទីនេះលេងហើយ »។

មករាលាន់មាត់ « ខ្ញុំស្រេកទឹកណាស់ »

រតនាក៏ឆ្លើយ « អូ! អត់បានទេ »

រតនានិយាយទាំងយំ ‹‹ យើងភ្លេចយកទឹកមកបាត់ទៅហើយ។ តើគួរធ្វើយ៉ាងណាទៅ? »



មករាក៏មានយោបល់ « ប្រហែលជាពួកយើងអាចបេះផ្លែដូងនៅដើមនេះបាន។
តើធ្វើយ៉ាងណាទើបបេះផ្លែដូងបានទៅណ៎? »




រតនារាប់ផ្លែដូងទាំងអស់ ដែលនៅលើដើមដូងនោះ។ នាងក៏បូកដកឃើញថា
បើពួកគេអាចបេះដល់ ពួកគេនឹងបានផ្លែដូងម្នាក់មួយ ហើយនៅសល់ដូងពីរផ្លែទៀតផង
តែបូកដកបែបនេះ មិនអាចជួយឱ្យពួកគាត់បេះផ្លែដូងបាននោះទេ។




មករាក៏និយាយ « ខ្ញុំអាចប្រកបពាក្យផ្លែដូងបានយ៉ាងល្អ។
ផ ជើង ល ដាក់ស្រៈ ែ ផ្លែ ដ ដាក់ស្រៈ ូ នឹង ង ខ្ញុំអានថាផ្លែដូង »
តែការដែលមករាចេះប្រកបពាក្យផ្លែដូងដូចនេះ មិនអាចជួយឱ្យពួកគាត់បេះផ្លែដូងបាន
សូម្បីតែមួយផ្លែឡើយ។



យ៉េកខំឈរចង្អើត លើកដៃឈោងទៅលើ តែទោះជាគាត់អាចលើកដៃបានខ្ពស់ប៉ុណ្ណាក៏ដោយ ក៏មិនខ្ពស់ដល់ថ្នាក់អាចបេះផ្លែដូងបានដែរ។



លោកគ្រូសុខឱនក្បាលចុះ ហើយរត់សម្រុកទៅបុកដើមដូងពេញមួយទំហឹង។
គាត់គិតថា ធ្វើយ៉ាងនេះអាចធ្វើឱ្យផ្លែដូងរង្គើធ្លាក់ចុះក្រោម។
តែចុងក្រោយ បែរជាគ្មានផ្លែដូងណាធ្លាក់មក សូម្បីតែមួយផ្លែសោះ។




ស្រាប់តែពេលនោះ មានដូងមួយផ្លែធ្លាក់មកក្អុក នៅជិតរតនាតែម្ដង
ធ្វើឱ្យពួកគាត់លោតភ្ញាក់ខ្លួនគ្រប់ៗគ្នា។
« ក្អុក! » ដូងមួយផ្លែទៀតធ្លាក់មកជិតមករាហើយ!
« ក្អុកៗ! »
« តើមានរឿងអ្វីកើតឡើងហ្នឹង? »



ពួកគេក៏នាំគ្នាងើយមើលទៅលើទាំងអស់គ្នា ឃើញខេទីនៅលើដើមដូង
កំពុងបេះផ្លែដូងជិតបានមួយផ្លែទៀតហើយ!
« ក្តុក! »
តោះទះដៃឱ្យខេទីទាំងអស់គ្នា ព្រោះគាត់បានជួយសង្គ្រោះអ្នកទាំងអស់គ្នា
ពីការស្រេកទឹកនៅគ្រានេះបានហើយ។



រតនាក៏និយាយ « ឃើញអត់ខេទី តាមពិតអ្នកពូកែទេតើ គឺពូកែខាងឡើងដើមឈើនោះអី »
មករាក៏និយាយបន្ត « មនុស្សម្នាក់ៗសុទ្ធតែពូកែមួយរឿងផ្សេងៗពីគ្នា »៕




# តើអ្នកពូកែអី?

អ្នកនិពន្ធ៖ TukTuk

អ្នកគំនូរ៖ ហិន ឆវិន

គំនូរជីវចល

ធនធានបង្រៀន

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

TUKTUK

Rotary
ROTARY INTERNATIONAL